# សិលាចារឹកប្រាសាទត្រពាំងថ្នល់ឈូក K.៣៥១

## ១- ព័ត៌មានទូទៅ

«ប្រាសាទត្រពាំងថ្នល់ឈូក» ឬនៅក្នុងសៀវភៅ «សិលាចារឹកនៃប្រទេសកម្ពុជា» ក្បាលទី៦របស់លោក ហ្សឺក សេដេស ហៅថា «ប្រាសាទថ្នល់ឈូក» ស្ថិតនៅក្នុងភូមិអូរក្សាន្ត ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ តាមរយៈគេហទំព័រ CISARK[១] បានឱ្យដឹងថា ទីកន្លែងនេះស្ថិតនៅចម្ងាយ ៨គ.ម. ពីអាគ្នេយ៍ស្រុកជាំក្សាន្ត។ បុរាណដ្ឋាននេះព័ទ្ធដោយកសិន្ធុនិងកំពែងឥដ្ឋរាងចតុកោណកែង មានខ្លោងទ្វារធ្វើពីឥដ្ឋនៅទិសខាងកើត។ ប្រាសាទនេះមានប្រាង្គប្រាំធ្វើពីឥដ្ឋ រត់ជួរជើង-ត្បូងមានពីរជួរ នៅខាងជួរខាងមុខមានប្រាង្គបីរាងបួនជ្រុងស្មើ និងជួរខាងក្រោយមានប្រាង្គពីរ រាងចតុកោណកែងបែរមុខទៅកើត ហើយមានហោត្រៃមួយនៅទិសឦសាន ចំណែកហោត្រៃមួយទៀតនៅទិសអាគ្នេយ៍។ រីឯនៅខាងកើតប្រាសាទមានស្រះមួយទទឹង ៨០ម និង បណ្តោយ ២០០ម។ ប្រាសាទនេះមានសិលាចារឹកពីរគឺសិលាចារឹក K.៣៥០ និងសិលាចារឹក K.៣៥១ ស្ថិតនៅមេទ្វារខាងត្បូងនៃប្រាង្គពាយ័ព្យ មាន ១៣បន្ទាត់ ចារជាភាសាខ្មែរ។

សិលាចារឹក K.៣៥១ ធ្លាប់បានអ្នកប្រាជ្ញខាងសិលាចារឹកលើកយកមកសិក្សារួចមកហើយដូចជាលោក ហ្សឺក សេដេស នៅក្នុងសៀវភៅ «សិលាចារឹកនៃប្រទេសកម្ពុជា» ក្បាលទី៦ ឆ្នាំ១៩៥៤ និងក្រោយមកគឺលោក ហ្វីលីព ចេណ្ណឺរ ដែលបានសិក្សាសិលាចារឹកនេះដែរនៅក្នុងស្នាដៃរបស់លោក Part xml, № 98 និងចុះផ្សាយនៅគេហទំព័រ http://sealang.net/ok/corpus.htm។[២]

អត្ថបទសិលាចារឹកនេះមានចំនួន១៣បន្ទាត់ ចារជាភាសាខ្មែរបុរាណ ចុះកាលបរិច្ឆេទនៅមហាសករាជឆ្នាំ៩១៤ ដែលត្រូវនឹងគ្រិស្តសករាជឆ្នាំ៩៩៣ ខ្លឹមសារសំខាន់នៃ

[១] https://cisark.mcfa.gov.kh/core/showsite.php?id=617

[២] សូមជ្រើសរើសលេខ «K.351»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

អត្ថបទនេះ គឺការឱ្យពរនិងបណ្តាសារបស់ព្រះសភាដល់អ្នកដែលលួចគ្រឿងតង្វាយឱ្យចុះនរក[៣] និងអ្នកធ្វើសេចក្តីចម្រើនដល់គ្រឿងតង្វាយឱ្យឡើងឋានសួគ៌ជាមួយគ្រួសាររបស់អ្នកទាំងនោះ ហើយក៏មានប្រាប់ពីឈ្មោះអ្នកបម្រើដែលឱ្យដើម្បីបម្រើប្រាសាទនិងបញ្ជាក់ប្រាប់ពីអ្នកដែលមានតួនាទីថែរក្សាតង្វាយ។

ព្រះសភា គឺជាក្រុមជំនុំមន្ត្រីកាត់ក្តី ពោលគឺតុលាការ។ ក្រុមនេះមានតួនាទីសំខាន់ណាស់កាលពីបុរាណ ក្នុងការចាត់ចែងរៀបចំក្នុងដំណើរការប្រព័ន្ធយុត្តិធម៌។ ចំពោះពាក្យ «សភា» នេះ នៅសម័យក្រោយមកក្លាយសូរមកជា «សូភា» និង «សុភា» ដូចមានក្នុងរឿងព្រេងនិទាន ដែលមានសត្វទន្សាយតំណាងឱ្យតួអង្គឈ្លាសវៃក្នុងការកាត់ក្តី ហៅថា «សុភាទន្សាយ»។

ចំពោះកាលបរិច្ឆេទ យើងសង្កេតឃើញមានប្រើប្រាស់ឆ្នាំសត្វតាមប្រតិទិនរបស់ចិន គឺឆ្នាំពោង (ពោងនក្សត្រ) ដែលសិលាចារឹកនេះ គឺជាសិលាចារឹកចំណាស់ជាងគេ ដែលបង្ហាញពីវត្តមាននៃការប្រើប្រាស់ឆ្នាំសត្វនេះ[៤]។ ឥទ្ធិពលនៃការប្រើប្រាស់នេះ ពេញនិយមខ្លាំងបំផុតចាប់ពីសម័យកណ្តាលមក ដែលយើងឃើញមានភស្តុតាងសិលាចារឹកសម័យកណ្តាលនៅប្រាសាទអង្គរវត្ត បានបង្ហាញយ៉ាងច្បាស់។ បច្ចុប្បន្ន ខ្មែររាប់អានឆ្នាំនេះយ៉ាងខ្លាំង រហូតហៅថា «ឆ្នាំខ្មែរ» ទៀតផង។

ចំពោះបណ្តាសា និងការឱ្យពរជ័យវិញ យើងឃើញថានៅបន្តមាននៅក្នុងសង្គមខ្មែរបច្ចុប្បន្នដដែល។ យើងឃើញមានភស្តុតាងនៅសម័យអង្គរជាច្រើន ដែលបង្ហាញអំពីការស្បថស្មោះស្ម័គ្រភក្តីចំពោះព្រះមហាក្សត្រ ស្បថចំពោះការទិញលក់ឬវិវាទដីធ្លីជាដើម។ ដូច្នេះហើយ យើងឃើញថាបច្ចុប្បន្ននេះ មន្ត្រីជាន់ខ្ពស់ដែលបំពេញនាទីក្នុងព្រឹទ្ធសភា រដ្ឋសភា គណៈរដ្ឋមន្ត្រី ថៅក្រម ព្រះរាជអាជ្ញាជាដើម តែងស្បថមុននឹងចូលកាន់តំណែង។ ឯបណ្តាសាវិញ ក៏ពេញនិយមណាស់នៅសម័យកណ្តាល ដ្បិតម្ចាស់បុណ្យមានបំណង

---

[៣] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/8475។

[៤] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/20098។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

រក្សាការពារបុណ្យឬធម៌ដែលខ្លួនបំពេញ ឱ្យមាននិរន្តរភាពជាដំណែលតទៅមុខជាដរាប កុំបីមាននរណាមកបំផ្លាញនោះឡើយ។

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើប

១- ៩១២គកទ្វាទគិ៥កេតវៃគាខអា

២- [ទិ]ត្យវារហស្តឫក្សពោងនក្សត្រ

៣- នេះគិពោះវរគាបយេងវ្រះសភាផោ

៤- ង៉ំនេះតៃថ្វាសនុកនិសោតិមនិស្តេញ

៥- អ្ពិគាន្តិ[ប]ទឱយិតស្តេញគិខាន្តរា

៦- ចាយ្យ៍បិស្តេញគិខាន្តរាចាយ្យ៍ចំចំ

៧- នាមរង្គោលិះ១ទ្វាទគីនាវ្រះកំម្រតេង

៨- នារាយនៈនៅតសប្បួ[៦]កល្បនានោ[ះ][៧]

៩- សកិស្រេខ្ញុំនោះគេទៅតទ្វាត្រឹគនរក

១០- នៅតវជេ៉[៨]នោះគេមានិស្វគ៌្គនុសន្តាន

១១- ផោងរំអាចិតិស្រចិតខ្ញោញិអ្ន

១២- កិនៅអ្នកិតប្រជានតនោះទេគ

១៣- នោះៈនោះគិតបរិបាលនៈ

## ៣- សេចក្តីប្រែសម្រួល

(១-២) មហាសករាជ៩១២ (គ.ស.៩៩៣) ថ្ងៃអាទិត្យ ១២កើត ខែពិសាខ ហស្តឫក្ស ឆ្នាំពោង។ នេះគឺពរនិងបណ្តាសារបស់យើង(ដែលជា)ព្រះសភាទាំងឡាយ។

---

[៥] លោក សេដេស និងលោក ចេណ្ណឹរ អានជា «គី» ប៉ុន្តែតាមរយៈការផ្ទៀងជាមួយសិលាចារឹកគឺ «គិ»។

[៦] លោក សេដេស និងលោក ចេណ្ណឹរ អានជា «លប្ប»។

[៧] លោក សេដេស និងលោក ចេណ្ណឹរ អានជា «នោះ» ។

[៨] លោក សេដេស និងលោក ចេណ្ណឹរ អានជា «វទ្វេំ» ប៉ុន្តែតាមរយៈការផ្ទៀងជាមួយសិលាចារឹកគឺ «វជេ៉»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

(៤-៨) នេះ(គឺ)នាងថ្នាសនិង(នាង)កន្សោត ដែលស្ដេញអ្ធិសាន្ទិបទឱ្យដល់ស្ដេញសិខាន្តពចារ្យ។ គប្បីស្ដេញសិខាន្តពចារ្យ មើលខុសត្រូវរៀបចំគ្រឿងវណ្ណាប់បូជា(មាន)អង្គរ១លិះនៅថ្ងៃទី១២(ទាំងខ្នើតនិងរនោច)នៅ(ប្រាសាទ)ព្រះគម្តែងនាពយណ៍។

(៨-១៣) នូវសព្វវណ្ណាប់តង្វាយបូជា (គឺនរណាដែល)យកស្រែ(និង)អ្នកបម្រើទាំងនោះ (សូមឱ្យ)គេចុះនរក៣២ជាន់។ នូវអ្នកដែលធ្វើឱ្យចម្រើន(ដល់តង្វាយ)នោះ (សូមឱ្យ)គេឡើងស្ថានសួគ៌ជាមួយសន្តានទាំងឡាយ។ (តង្វាយទាំងអស់នោះ)ពុំអាចសម្រេចលើប្រធានអ្នកបម្រើ(ឡើយ) (គឺ)នៅ(លើ)អ្នកដែលជាប្រធានភូមិស្រុកនោះ ជាអ្នកថែរក្សា។

## ៤- ពន្យល់ពាក្យ

| | |
|---|---|
| **ទ្វាទឝិ** | (សំ. ទ្វា "ពីរ" + ទឝិ "ទីដប់") ទី១២។ |
| **វៃឝាខ** | (សំ.) ខែពិសាខ។ |
| **វរឝាប** | (សំ. វរ "ពរ" + ឝាប "សម្បថ, បណ្ដាសា) ពរនិងបណ្ដាសា។ |
| **ចំចំនាម** | (ចំ "ចាំ, នៅមើលថែរក្សា", ចំនាម "បទបញ្ជាផ្ទៃក្នុងទាក់ទងនឹងគ្រឿងវណ្ណាប់បូជា"[៩]) រៀបចំ ឬមើលការខុសបទបញ្ជាផ្ទៃក្នុងទាក់ទងនឹងគ្រឿងវណ្ណាប់បូជាក្នុងប្រាសាទ។ |
| **សប្វ** | សព្វ, សព្វគ្រប់បែបយ៉ាង។ |
| **កល្បនា** | (សំ.) គ្រឿងវណ្ណាប់បូជា, តង្វាយ។ |
| **សក៌** | លួច យកចេញ ដកចេញ។ |
| **ទ្វាត្រឹឝ** | (សំ. ទ្វា "ពីរ" + ត្រឹឝ "ទីសាមសិប") ៣២ |
| **វធ៌** | (សំ.) ធ្វើឱ្យចម្រើនលូតលាស់ទៅមុខ។ |

[៩] សូមអានបន្ថែមទាក់ទងនឹងពាក្យនេះ http://www.yosothor.org/publications/khmer-renaissance/chapter-six/cham-nam.html

# ឯកសារយោង


CISARK. Trâpeang Thnâl Chhouk. https://cisark.mcfa.gov.kh/core/showsite.php?id=617

Cœdès, G. 1954. Inscriptions de Pràsàt Thnăl Čhuk (K. 350, K.351) in Inscriptions du Cambodge, Vol. 6. Paris.

Jenner, P. Piédroit of Pràsàt Thnăl Čhuk in Part xml, № 98. http://sealang.net/ok/corpus.htm


# បញ្ជីរូបភាព



n. 774 / K. 351

សំណៅផ្តិតសិលាចារឹកប្រាសាទត្រពាំងថ្នល់ឈូក K.៣៥១ (ប្រភពរូប៖ EFEO ដកពី CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



ប្រាសាទត្រពាំងថ្នល់ឈូក (ប្រភពរូបៈ CISARK)



ប្រាសាទត្រពាំងថ្នល់ឈូក (ប្រភពរូបៈ CISARK)

អត្ថបទដោយៈ ហ៊ុន ឈុនតេង